ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

**ចំណាប់អារម្មណ៍របស់**
**លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ក្នុងសិក្ខាសាលាពិគ្រោះយោបល់លើការរៀបចំក្របខ័ណ្ឌ ស្ដីពី**
**"ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី"**

ថ្ងៃព្រហស្បតិ៍ ១០រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤
សណ្ឋាគារ Raffle Hotel Le Royal

**សូមគោរព៖**

- *លោកជំទាវគតិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី*
- *លោកស្រី Cristina Maynes នាយិការប្រចាំតំបន់អាស៊ីអាគ្នេយ៍ នៃអង្គការ Women's World Banking*
- *លោកជំទាវ ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញា តំណាងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាក្រៃលែងដែលបានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់លើការរៀបចំក្របខ័ណ្ឌ ស្តីពី **"ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី"** នាពេលនេះ។ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរខ្ពស់ចំពោះសមិទ្ធិផល និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងកិច្ចការនារី ក្នុងការអនុវត្តយុទ្ធសាស្ត្រនារីរតនៈ និងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ នាពេលកន្លងមក សំដៅជំរុញលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការរបស់ស្ត្រី និងសហគ្រិនស្ត្រី ព្រមទាំងចូលរួមចំណែកក្នុងការជំរុញកំណើនប្រកបដោយចីរភាព។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមឆ្លៀតយកឱកាសនេះដើម្បីថ្លែងអំណរគុណចំពោះក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍នានា ពិសេស


ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៥ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

អង្គការ Women's World Banking ដែលជានិច្ចកាលតែងតែគាំទ្រដល់ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីនៅកម្ពុជានាពេលកន្លងមក។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីមេត្រី!**

បរិយាបន្នហិរញ្ញវត្ថុ ដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់វិបុលភាពនៅកម្ពុជា។ ការជំរុញការទទួលបានសេវាហិរញ្ញវត្ថុដែលមានតម្លៃសមរម្យ និងការប្រើប្រាស់សេវាទាំងនេះបានត្រឹមត្រូវតាមគោលដៅ នឹងផ្តល់ផលប្រយោជន៍ជាច្រើនទាំងផ្នែកសង្គម និងផ្នែកសេដ្ឋកិច្ច។

គិតត្រឹមឆ្នាំ២០១៥ ប្រជាជនពេញវ័យនៅកម្ពុជាប្រមាណ ៥៩% ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ ហើយកម្រិតបរិយាបន្នហិរញ្ញវត្ថុសម្រាប់ប្រជាជនទាំងពីរភេទ គឺប្រហាក់ប្រហែលគ្នា ដោយស្ត្រីមាន ៧៣% ខ្ពស់ជាងបុរសបន្តិចដែលមានត្រឹម ៦៩%។ ជាមួយគ្នានេះ ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា មានបញ្ហាប្រឈមមួយចំនួនដូចជា បញ្ហាហេដ្ឋារចនាសម្ព័ន្ធ បញ្ហាប្រាក់ចំណូល លទ្ធភាពក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនានារបស់អ្នកផ្តល់សេវា ភាពមានកម្រិតនៃសេវានិងផលិតផលហិរញ្ញវត្ថុនៅលើទីផ្សារ និងកង្វះការយល់ដឹងផ្នែកហិរញ្ញវត្ថុ។ ដូច្នេះដើម្បីជំរុញបរិយាបន្នហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រជាតិស្តីពី **"បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥"** នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដោយបានកំណត់គោលដៅក្នុង **"ការបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព កាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុឱ្យបានពាក់កណ្តាលពី ២៧% មក ១៣% និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី ៥៩% ទៅ ៧០% ត្រឹមឆ្នាំ២០២៥ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពគ្រួសារ និងគាំទ្រកំណើនសេដ្ឋកិច្ច"**។

ជាមួយគ្នានេះ ការសិក្សាជាច្រើនបានបង្ហាញថានៅពេលស្ត្រីកាន់តែច្រើនមានលទ្ធភាពទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ពួកគេនឹងចូលរួមក្នុងការអភិវឌ្ឍគ្រួសារ និងសហគមន៍ច្រើនជាងបុរស តាមរយៈលើកកម្ពស់ជីវភាពរស់នៅ ការបង្កើនឱកាសអាជីវកម្ម ការសន្សំ និងការត្រៀមខ្លួនទប់ទល់នឹងបញ្ហាហិរញ្ញវត្ថុនាពេលមានអាសន្ន ដែលកត្តាទាំងនេះនឹងនាំឱ្យគ្រួសារ និងសហគមន៍របស់ពួកគេមានលទ្ធភាពច្រើនជាងមុនក្នុងការទទួលបានសេវាចាំបាច់នានា ដូចជាសេវាអប់រំ សេវាសុខភាព អនាម័យ និងទឹកស្អាត ជាដើម។ ប៉ុន្តែ ស្ត្រីត្រូវជួបប្រទះនឹងបញ្ហាប្រឈមច្រើនជាងបុរស ដើម្បីទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ ហើយបញ្ហាប្រឈម

ដែលសំខាន់បំផុតគឺផ្នត់គំនិតប្រកាន់នូវវប្បធម៌ប្រពៃណី ដែលជាទូទៅរារាំងស្ត្រីពីការសម្រេចចិត្ត លើបញ្ហាហិរញ្ញវត្ថុគ្រួសារ និងឱកាសអាជីវកម្ម។

គិតត្រឹមឆ្នាំ២០២០ កម្ពុជាមានប្រជាជនសរុបចំនួន ១៦,៤ លាននាក់ ក្នុងនោះស្ត្រីមាន ៥០,៥% ហើយស្ត្រីប្រមាណ៧៥% រស់នៅតាមតំបន់ជនបទ និងប្រកបមុខរបរធ្វើស្រែចំការ ព្រមទាំងជាអាជីករខ្នាតមីក្រូ និងតូច។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីមេត្រី!**

បន្ទាប់ពីអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ បានមួយរយៈ ធនាគារជាតិនៃកម្ពុជា ក្រោមជំនួយបច្ចេកទេសពីអង្គការ UNCDF បានរៀបចំការអង្កេតថ្មីមួយ ដែលមានឈ្មោះថា "Mobile Tracker Survey" នៅឆ្នាំ២០២១ ដើម្បីពិនិត្យអំពីវឌ្ឍនភាពនៃ កម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា និងប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពអាទិភាព នានា។ ជាលទ្ធផល អត្រាប្រជាពលរដ្ឋពេញវ័យដែលទទួលបានសេវាហិរញ្ញវត្ថុផ្លូវការបានកើន ឡើងពី ៥៩% ទៅ ៦៧% ហើយអត្រាការទទួលបានសេវាហិរញ្ញវត្ថុក្រៅផ្លូវការបានថយចុះពី ២៩% មក ត្រឹម ១៧%។ ប៉ុន្តែ ការដែលគួរឱ្យសោកស្តាយគឺការអង្កេតនេះបានបង្ហាញផងដែរថា អត្រាស្ត្រីដែលទទួលបានសេវាហិរញ្ញវត្ថុផ្លូវការហាក់នៅដដែល ខណៈដែលស្ត្រីដែលធ្លាប់ទទួល បានសេវាហិរញ្ញវត្ថុក្រៅផ្លូវការ ថយចុះប្រមាណ ១២% ផងដែរ។ ការណ៍នេះ បង្ហាញថាស្ត្រី និង ស្ត្រីជាម្ចាស់សហគ្រាសធនមីក្រូនិងតូច ទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរពីវិបត្តិសុខាភិបាលសកល កន្លងទៅនេះ ដែលបានធ្វើឱ្យស្ត្រីមួយចំនួនត្រូវបានកាត់ផ្តាច់ទាំងស្រុងពីការទទួលបានសេវា ហិរញ្ញវត្ថុ ទោះផ្លូវការ ឬ ក្រៅផ្លូវការ។

ក្នុងបរិបទនេះ ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុគួរត្រូវបានយកចិត្តទុកដាក់បន្ថែម ដើម្បី គាំទ្រការងើបឡើងវិញនៃសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចគ្រួសារ ហើយការលើកកម្ពស់ កម្រិតបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីនឹងជួយបន្ថែមនូវតួនាទីរបស់ស្ត្រីនៅក្នុងសេដ្ឋកិច្ច តាមរយៈ ការបង្កើនឱកាសធុរកិច្ច ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ និងការបង្កើនលទ្ធភាពសន្សំ។

ក្នុងនាមជាស្ថាប័នដឹកនាំការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ធនាគារជាតិ នៃកម្ពុជា តែងតែយកចិត្តទុកដាក់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុតាមរយៈការដាក់ចេញ បទប្បញ្ញត្តិនានា ដូចជា ប្រកាសស្តីពីលក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការ ធ្វើអាជីវកម្មប៊ែងកាសួរេន ប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទាន ប្រកាសស្តីពីការដោះ ស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាដើម។ ថ្មីៗនេះ ធនាគារជាតិនៃ កម្ពុជា បានចេញប្រកាសស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតគ្រប់គ្រាន់នៃដើមទុនរបស់

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដើម្បីគាំទ្រនិងលើកទឹកចិត្តដល់ការផ្តល់ឥណទានទៅសហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលបាន ចុះបញ្ជីត្រឹមត្រូវនិងមានរបាយការណ៍ហិរញ្ញវត្ថុសមស្រប និង ការគាំទ្រការផ្តល់ឥណទានដល់ហិរញ្ញប្បទានបៃតង ជាដើម។ បន្ថែមលើនេះ ស្របតាមបរិបទនៃការរស់នៅក្នុងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជា បានបង្កើតនូវប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់ប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន ដោយអនុញ្ញាតឱ្យអ្នកប្រើប្រាស់ក៏ដូចជាធុរជន អាចធ្វើការទូទាត់ និងផ្ទេរប្រាក់ភ្លាមៗពីគ្រឹះស្ថានមួយទៅគ្រឹះស្ថានមួយ តាមរយៈកម្មវិធីធនាគារនៅលើទូរស័ព្ទដៃប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព។

ទន្ទឹមនឹងការជំរុញបរិយាបន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក៏យកចិត្តទុកដាក់ផងដែរក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ តាមរយៈកិច្ចសហការជាមួយក្រសួង-ស្ថាប័នជាតិនិងអន្តរជាតិ ដូចជាៈ

- ក្រសួងកិច្ចការនារី ក្នុងការអនុវត្តគម្រោង "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី" ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ លើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងហិរញ្ញវត្ថុរបស់ស្ត្រី
- ក្រសួង អប់រំ យុវជននិងកីឡា ដោយដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុង កម្មវិធីសិក្សាចំណេះទូទៅ ចាប់ពីថ្នាក់ទី១ ដល់ទី១២
- អង្គការ UNESCAP ដើម្បីអនុវត្តគម្រោង "ការជំរុញសហគ្រិនភាពរបស់ស្ត្រី (Catalyzing Women's Entrepreneurship)" ក្នុងគោលដៅបង្កើនការយល់ដឹង និង លទ្ធភាពទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការសម្រាប់ស្ត្រី និងសហគ្រិនជាស្ត្រី
- អង្គការ Good Return ក្នុងការរៀបចំយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយ" និង "តោះ! និយាយពីលុយៈ តក់ៗពេញបំពង់" និង
- ការផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ក្នុងគោលដៅបន្តពង្រឹងចំណេះដឹងពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ ការធានាឱ្យមានការរីកចម្រើនប្រកបដោយប្រសិទ្ធភាព ស្ថិរភាព តម្លាភាព និងការពារអត្ថប្រយោជន៍ជូនប្រជាជន។

ក្នុងទិសដៅជំរុញការសម្រេចបាននូវគោលដៅកាត់បន្ថយអត្រាស្ត្រី ដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុ ការប្រមូលទិន្នន័យប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ស្ត្រីពិតជាមានសារៈសំខាន់ និងចាំបាច់បំផុត។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា បានសហការជាមួយ សហព័ន្ធប

រិយាបន្នហិរញ្ញវត្ថុ (AFI) អនុវត្តគម្រោងប្រមូលទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមភេទ ដោយរួមបញ្ចូលនូវក្របខណ្ឌនិងផែនទីចង្អុលផ្លូវច្បាស់លាស់ សម្រាប់ការប្រមូលនិងវិភាគទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមភេទរបស់អ្នកប្រើប្រាស់ ក៏ដូចជាសហគ្រាស ធុនមីក្រូ តូច និងមធ្យម។ ទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមភេទនេះ នឹងគាំទ្រដល់ការវាយតម្លៃនិន្នាការនៃការផ្តល់សេវាហិរញ្ញវត្ថុសម្រាប់ស្ត្រី និងការតាមដានគម្លាតនៃការទទួលបានសេវាហិរញ្ញវត្ថុរវាងស្ត្រីនិងបុរស ដើម្បីជាមូលដ្ឋានក្នុងការវាស់វែងការអនុវត្តយុទ្ធសាស្ត្រជាតិ ក៏ដូចជាដាក់ចេញនូវគោលនយោបាយ និងវិធានការដើម្បីបន្តជំរុញការផ្តល់និងការទទួលបានសេវាហិរញ្ញវត្ថុរបស់ស្ត្រី។

អ្វីដែលយើងមិនអាចបំភ្លេចបាននោះគឺ កិច្ចសហការជិតស្និទរវាងធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី ក្រោមក្របខ័ណ្ឌនៃអនុស្សរណៈនៃការយោគយល់រវាងស្ថាប័នទាំងពីរ។ ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី ធ្លាប់ចុះអនុស្សរណៈលើកដំបូងនៅឆ្នាំ២០១៩ ដោយផ្តោតលើការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី តាមរយៈការលើកកម្ពស់ចំណេះដឹងផ្នែហិរញ្ញវត្ថុរបស់ស្ត្រី និងសហគ្រិនស្ត្រី។ ថ្មីៗកន្លងទៅនេះ យើងបានចុះអនុស្សរណៈម្តងទៀតដើម្បីបន្ត និងពង្រីកវិសាលភាពនៃកិច្ចសហការ ហើយការរៀបចំក្របខ័ណ្ឌ ស្តីពី **"ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី"** នេះ គឺជាការបោះជំហានថ្មីមួយគួរជាទីមោទនៈ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីមេត្រី!**

ការរៀបចំក្របខ័ណ្ឌស្តីពីការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការសម្រេចបានគោលដៅដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិ ហើយក្របខ័ណ្ឌនេះក៏នឹងដើរតួយ៉ាងសំខាន់ក្នុងការចង្អុលបង្ហាញអំពីទិសដៅ និងសកម្មភាពអាទិភាពដែលយើងទាំងអស់គ្នាត្រូវសហការអនុវត្តដើម្បីគោលដៅរួម។ ហេតុដូច្នេះ ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់នាថ្ងៃនេះ គឺជាចំណុចចាប់ផ្តើមយ៉ាងសំខាន់ ដែលទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

ខ្ញុំសង្ឃឹមថាសិក្ខាសាលាពិគ្រោះយោបល់នាថ្ងៃនេះ នឹងបង្កើនការយល់ដឹងដល់សិក្ខាកាម និងភាគីពាក់ព័ន្ធ អំពីស្ថានភាពបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីនៅកម្ពុជា បញ្ហាប្រឈម និងតម្រូវការនានា។ ខ្ញុំសូមលើកទឹកចិត្តឱ្យសិក្ខាកាមទាំងអស់ផ្តល់ការយកចិត្តទុកដាក់ និងចូលរួមឱ្យបានសកម្មជាគំនិត យោបល់ និងធាតុចូលផ្សេងៗដើម្បីជាបច្ច័យសម្រាប់បន្តកិច្ចការរៀបចំក្របខ័ណ្ឌស្តីពីបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី របស់យើងឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយមានលក្ខណៈវិទ្យាសាស្ត្រខ្ពស់ និងស្របតាមតម្រូវការផ្នែកហិរញ្ញវត្ថុរបស់ស្ត្រី និងសហគ្រិនជាស្ត្រីរបស់ប្រជាជាតិយើងទាំងមូល (Gener sensitive and gender responsive policy)។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ លោកជំទាវរដ្ឋមន្ត្រី លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ សូមជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**